ព្រឹត្តិបត្រព័ត៌មានអំពីផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ ACCESS 2

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

កម្មវិធី ACCESS 2 កំពុងពង្រឹងការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) ដើម្បីឱ្យស្ត្រី និងក្មេងស្រីដែលរងអំពើហិង្សាអាចទទួលបានសេវាដែលមានសុវត្ថិភាព គុណភាព និងផ្តោតលើអ្នកនៅរស់រានមានជីវិតជាស្នូល។ តាមរយៈកិច្ចសហការជាមួយក្រសួងកិច្ចការនារី រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូសង្គមស៊ីវិល កម្មវិធី ACCESS 2 គាំទ្រដល់ការអនុវត្តគោលនយោបាយ ការផ្តល់សេវា និងការសម្របសម្រួលជាពហុវិស័យ។ តាមរយៈបន្ទប់ប្រឹក្សាដែលរក្សាការសម្ងាត់ កន្លែងផ្តល់សេវាចម្រុះ (OSSU) សម្រាប់អ្នកនៅរស់រានមានជីវិតពី GBV ប្រព័ន្ធបញ្ជូនករណីបន្ត និងការកសាងសមត្ថភាពដល់អ្នកផ្តល់សេវាជួរមុខ កម្មវិធីនេះកំពុងជួយកសាងប្រព័ន្ធឆ្លើយតបនឹង GBV ដែលមានការសម្របសម្រួលកាន់តែប្រសើរ ងាយស្រួលទទួលបាន និងប្រកបដោយនិរន្តរភាព ដែលរួមចំណែកលើកកម្ពស់សុវត្ថិភាព ការគាំទ្រ និងការស្តារឡើងវិញសម្រាប់អ្នកនៅរស់រានមានជីវិត។

ទិដ្ឋភាពរួមផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- បានផ្តល់ការគាំទ្រផ្នែកGBV បាន ៤.៦៦២ ករណី
- បានផ្តល់សេវាកិច្ចអន្តរាគមន៍ចំនួន ៧.៥៦៧ លើក
- អ្នកផ្តល់សេវាជួរមុខ ១.៨៧៥នាក់ ទទួលបានការបណ្តុះបណ្តាល
- អ្នកផ្តល់សេវាថែទាំសុខភាព ៣៤៥នាក់ ទទួលបានការបណ្តុះបណ្តាល
- បានពង្រឹងក្រុមការងារឆ្លើយតប GBV ចំនួន៣៣ក្រុម
- បានបង្កើតបន្ទប់ប្រឹក្សាយោបល់ ដែលរក្សាការសម្ងាត់ បានចំនួន៦៧
- បង្កើតកន្លែងផ្តល់សេវាចម្រុះ ចំនួន៣កន្លែង
- ប្រជាជនជាង៤0.000 នាក់ បានទទួលព័ត៌មានអំពីការទប់ស្កាត់ GBV
- ៨៧% នៃអ្នកទទួលសេវាពេញចិត្តយ៉ាងខ្លាំងចំពោះការផ្តល់សេវា

តើកម្មវិធី ACCESS 2 អនុវត្តសកម្មភាពអ្វីខ្លះ?

១ ពង្រឹងគោលនយោបាយ និងការសម្របសម្រួល

គាំទ្រគោលនយោបាយ គោលការណ៍ណែនាំ និងប្រព័ន្ធសម្របសម្រួលដែលពង្រឹងការឆ្លើយតបរបស់កម្ពុជាទៅនឹងអំពើហិង្សាលើស្ត្រី។

២ ធ្វើឱ្យគុណភាពនៃការផ្តល់សេវាកាន់តែប្រសើរ

កសាងសមត្ថភាពអ្នកផ្តល់សេវាជួរមុខ និងអ្នកផ្តល់សេវាថែទាំសុខភាព ដើម្បីផ្តល់សេវាប្រកបដោយគុណភាព និងផ្តោតជាសំខាន់ទៅលើអ្នកនៅរស់រានមានជីវិតជាស្នូល។

៣ ពង្រីកការទទួលបានសេវា

គាំទ្រដល់កន្លែងផ្តល់សេវាចម្រុះ និងពង្រឹងប្រព័ន្ធបញ្ជូនបន្ត ដើម្បីឱ្យអ្នកនៅរស់រានមានជីវិត អាចទទួលបានសេវាដែលនៅជិតផ្ទះរបស់ពួកគាត់។

៤ ជំរុញការឆ្លើយតបជាពហុវិស័យ

ពង្រឹងកិច្ចសហការរវាងរដ្ឋាភិបាល សេវាសុខាភិបាល ស្ថាប័នអនុវត្តច្បាប់ និងអង្គការសង្គមស៊ីវិល។



សកម្មភាពលេចធ្លោរបស់ផ្នែក GBV

កិច្ចប្រជុំក្រុមការងារ GBV

កិច្ចប្រជុំប្រចាំឆមាសផ្នែកក្រុមការងារ GBV ប្រមូលផ្តុំដៃគូរដ្ឋាភិបាល ដៃគូអនុវត្តជាយុទ្ធសាស្ត្រផ្នែក GBV និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យមើលវឌ្ឍនភាព ចែករំលែកមេរៀនដែលរៀនសូត្របាន និងកំណត់អាទិភាពសម្រាប់ការពង្រឹងការទប់ស្កាត់ និងការឆ្លើយតប GBV។ កិច្ចពិភាក្សាផ្តោតលើគុណភាពនៃការផ្តល់សេវា ការបញ្ជូនបន្ត ការសម្របសម្រួល ការផ្តោតលើអ្នកនៅរស់រានមានជីវិតជាស្នូល និងការបញ្ជៀបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងការរៀបចំផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ។

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ដៃគូ សកម្មភាព និងលទ្ធផល

តើយើងធ្វើការជាមួយអ្នកណាខ្លះ?

ភាពជាដៃគូជាមួយរាជរដ្ឋាភិបាល

- ក្រសួងកិច្ចការនារី
- ក្រសួងសុខាភិបាល
- មន្ទីរកិច្ចការនារីខេត្ត
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- មន្ទីរសុខាភិបាលខេត្ត
- ក្រុមការងារឆ្លើយតប GBV

ដៃគូអនុវត្តជាយុទ្ធសាស្ត្រ

- អង្គការ UNFPA / UN Women
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
- អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (TPO Cambodia)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការ CARE កម្ពុជា

សកម្មភាពចម្បងៗ

១ គោលនយោបាយ និងការសម្របសម្រួលកាន់តែរឹងមាំ

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ (NAPVAW IV) ត្រូវបានអនុម័ត គោលការណ៍ណែនាំជាតិស្តីពី OSSU ត្រូវបានអនុម័ត នីតិវិធីប្រតិបត្តិស្តង់ដា (SOP) សម្រាប់ OSSU ត្រូវបានរៀបចំឡើង រីឯ SOP ស្តីពីការគ្រប់គ្រងករណី GBV ក៏ត្រូវបានបង្កើត និងសាកល្បងអនុវត្ត ព្រមទាំង SOP ស្តីពីការសម្របសម្រួល GBV ក៏ត្រូវបានបង្កើតឡើង។

២ ធ្វើឱ្យគុណភាពសេវាកាន់តែប្រសើរ

ក្រុមការងារឆ្លើយតបGBV ចំនួន៣៣ ត្រូវបានពង្រឹង។ អ្នកផ្តល់សេវាជួរមុខចំនួន ១.៨៧៥ នាក់ និងអ្នកផ្តល់សេវាសុខាភិបាលចំនួន ៣៤៥នាក់ ទទួលបានវគ្គបណ្តុះបណ្តាល។ ៨៧% នៃអ្នកទទួលសេវា ពេញចិត្តយ៉ាងខ្លាំងចំពោះសេវាដែលពួកគាត់បានទទួល។

៣ ការពង្រីកសេវា ដែលផ្តោតលើអ្នកនៅរស់រានមានជីវិតជាស្នូល

បានបង្កើតបន្ទប់ប្រឹក្សាយោបល់ ដែលរក្សាការសម្ងាត់ចំនួន ៦៧ និងបង្កើត OSSU ចំនួន៣កន្លែង ព្រមទាំងបានផ្តល់ការគាំទ្រចំនួន ៤.៦៦២ករណី ក្នុងចំណោមសេវាអន្តរាគមន៍ចំនួន ៧.៥៦៧ ករណី។

៤ ការទប់ស្កាត់ និងការលើកកម្ពស់ការយល់ដឹង

ប្រជាពលរដ្ឋជាង ៤០.០០០នាក់ បានទទួលព័ត៌មានអំពីវិធានការទប់ស្កាត់ សិទ្ធិ និងសេវាគាំទ្រដែលមានស្រាប់។

សកម្មភាពលើកកម្ពស់ការយល់ដឹង និងការទទួលបានសេវា







អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org

www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global